**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រុមប្រឹក្សាស្ថិតិ**

# កំណត់ហេតុ

# ស្តីពី

# ការប្រជុំក្រុមប្រឹក្សាស្ថិតិ

នៅថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ២០០៧

ឆ្នាំ ពីរពាន់ប្រាំពីរ ខែ មេសា ថ្ងៃទី សាមសិប វេលាម៉ោងប្រាំបីនិងសាមសិបនាទី នៅសាលប្រជុំវិទ្យាស្ថានជាតិស្ថិតិមានបើកអង្គប្រជុំក្រុមប្រឹក្សាស្ថិតិ ក្រោមអធិបតីភាព ឯកឧត្តម **ឆាយ ថន** ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី ក្រសួងផែនការ ជាប្រធានក្រុមប្រឹក្សាស្ថិតិ ។ សមាសភាពក្រុមប្រឹក្សាស្ថិតិអញ្ជើញចូលរួមប្រជុំមានឯកឧត្តម រដ្ឋលេខាធិការ មកពីបណ្តាក្រសួង និងសមាជិកដទៃទៀតចូលរួមចំនួន ១៤ រូប បានចូលរួមតាមការអញ្ជើញរបស់ប្រធាន ដោយឡែកមានអវត្តមានសមាជិកមកពីក្រសួង ៥ គឺៈ

១- ក្រសួងអភិវឌ្ឍន៍ជនបទ

២- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

៣- ក្រសួង អប់រំ យុវជន និងកីឡា

៤- ក្រសួង សង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

៥- ក្រសួង កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

ជាកិច្ចចាប់ផ្តើមឯកឧត្តមទេសរដ្ឋមន្ត្រីរដ្ឋមន្ត្រីក្រសួងផែនការ ប្រធានក្រុមប្រឹក្សាស្ថិតិបានស្វាគមន៍បើកអង្គប្រជុំដោយមានមតិៈ

អង្គប្រជុំនេះជាកិច្ចប្រជុំលើកទី ១ របស់ក្រុមប្រឹក្សាស្ថិតិយើង ហើយក៏ដើម្បីឆ្លងផែនការមេស្ថិតិ ដែលជាកិច្ចការមួយយ៉ាងសំខាន់ក្នុងការអភិវឌ្ឍន៍ប្រព័ន្ធស្ថិតិជាតិ ។ ការរៀបចំផែនការមេស្ថិតិ មានសារៈប្រយោជន៍សំរាប់កំណត់ក្របខ័ណ្ឌការងារ ទំហំការងារ អាទិភាពការងារ តម្រូវការធនធាន ថវិកាសំរាប់អនុវត្តការងារស្ថិតិឱ្យមានប្រសិទ្ធភាព ។ អង្គប្រជុំនេះបង្ហាញពី កិច្ចអភិវឌ្ឍន៍ដ៏ចំបងនៃរចនាសម្ព័ន្ធ និងការរៀបចំរបស់ប្រព័ន្ធស្ថិតិជាតិ ។ ច្បាប់ស្ថិតិបានចូលជាធរមានកាលពីខែ ឧសភា ឆ្នាំ២០០៥ ហើយអនុក្រឹត្យស្តីពីការរៀបចំ និងកិច្ចដំណើរការរបស់ប្រព័ន្ធស្ថិតិជាតិបានចាប់ផ្តើមកសាងនូវក្របខ័ណ្ឌសំរាប់ការសម្របសម្រួល សហប្រតិបត្តិការដ៏មានប្រសិទ្ធភាព ដើម្បីឱ្យប្រព័ន្ធស្ថិតិជាតិមានដំណើរការល្អ ។ ក្របខ័ណ្ឌនៃកិច្ចអភិវឌ្ឍន៍ស្ថិតិនៅកម្ពុជា គឺផែនការមេស្ថិតិដែលយើងត្រូវពិភាក្សាអនុម័ត នៅថ្ងៃនេះ ។

ផែនការមេស្ថិតិកំណត់នូវផែនការ សកម្មភាពប្រមូលទិន្នន័យដ៏សមស្រប ដើម្បីបានព័ត៌មានដែលជាតម្រូវការរៀបចំគោលនយោបាយ និងកម្មវិធីនានា ។ ចំពោះដំណើរការនៃការអនុវត្តផែនការមេស្ថិតិ នៅពេលបានការអនុម័តពីក្រុមប្រឹក្សាស្ថិតិលើផែនការមេស្ថិតិហើយនោះ យើងនឹងផ្ញើជូនទីស្តីការគណៈរដ្ឋមន្ត្រី ដើម្បីពិនិត្យ និងអនុម័ត ។

តមកឯកឧត្តមប្រធានបានអញ្ជើញ ឯកឧត្តម អគ្គនាយកវិទ្យាស្ថានជាតិស្ថិតិ ធ្វើបទបង្ហាញអំពីការងារ សំខាន់ៗ របស់ផែនការមេស្ថិតិ :

ឯកឧត្តមអគ្គនាយក បានលើកឡើង ពីវឌ្ឍនភាព និងការផលិតស្ថិតិរយៈកាលកន្លងមកបានទទួលលទ្ធផលគួរកត់សំគាល់ ដោយមានការចូលរួមចំណែកដ៏ច្រើនពីដៃគូរអភិវឌ្ឍន៍ ។ យើងបានផលិតជាស៊េរី នៃការអង្កេតនានាជាច្រើន ។ ដើម្បីឱ្យការផលិតទិន្នន័យស្ថិតិប្រព្រឹត្តទៅរលូន យើងត្រូវធ្វើការរៀបចំផែនការមេស្ថិតិ ដែលកំណត់នូវផែនការរយៈពេលវែងមានអាទិភាពសំរាប់ប្រព័ន្ធស្ថិតិ ។ ផែនការមេស្ថិតិផ្តល់នូវយុទ្ធសាស្ត្ររយៈពេលវែង និងផែនការបរិញ្ញត្តដែលត្រូវការសំរាប់ធ្វើផែនការសកម្មភាពស្ថិតិ ។ កម្មវិធីជំរឿនអង្កេតមានរួមបញ្ចូល :

-ជំរឿនប្រជារាស្ត្រ ធ្វើនៅខែ មីនា ឆ្នាំ២០០៨

-ជំរឿនកសិកម្ម គ្រោងធ្វើ បើសិនណាមានថវិកានៅចុងឆ្នាំ២០០៩

-ជំរឿនសហគ្រាស គ្រោងនឹងធ្វើនៅឆ្នាំ ២០១១

ចំពោះការបណ្តុះបណ្តាលធនធានមនុស្សមកដល់ពេលនេះ មន្ត្រីវិទ្យាស្ថានជាតិស្ថិតិ ព្រមទាំងមន្ត្រីតាមបណ្តាក្រសួង ខេត្ត-ក្រុងផងដែលបានចូល បណ្តុះបណ្តាលជំនាញស្ថិតិ កុំព្យូទ័រ បានយ៉ាងច្រើនគួរសមដែរតាមរយៈជំនួយរបស់អង្គការ JICA តែការងារស្ថិតិ ជាការងារវិវត្តឥតឈប់ឈរ ដូច្នេះការបណ្តុះបណ្តាលក៏ត្រូវតែធ្វើបន្តបន្ទាប់ដែរ ។ នៅក្នុងផែនការមេស្ថិតិនៅឆ្នាំ២០១៥ ការងារស្ថិតិ នឹងត្រូវដំណើរការដោយថវិការដ្ឋស្ទើរតែទាំងស្រុង ។

បន្ទាប់ពីលោក Andrew Pinney ទីប្រឹក្សា UNDP បានលើកឡើងពីភារកិច្ចរបស់ក្រុមប្រឹក្សាស្ថិតិ និងគណៈកម្មាធិការសម្របសម្រួលស្ថិតិពិសេសជុំវិញការអនុវត្តន៍ច្បាប់ស្តីពីស្ថិតិ និងអនុក្រឹត្យស្តីពីការរៀបចំ និងកិច្ចដំណើរការ របស់ប្រព័ន្ធស្ថិតិជាតិ ក៏ដូចជាលើកឡើងពីអនុក្រឹត្យស្តីពី ស្ថិតិផ្លូវការដែលបានចាត់តាំងដែល នឹងត្រូវដាក់ឆ្លងនៅពេលខាងមុខ រួចមកអង្គប្រជុំបានធ្វើការពិភាក្សាយ៉ាងផុលផុសពីបញ្ហាផ្សេងៗដែលពាក់ព័ន្ធ ÷

- ឯកឧត្តម អេង ហួត រដ្ឋលេខាធិការក្រសួងសុខាភិបាលមានមតិថា : ការរៀបចំ ផែនការមេស្ថិតិតាមជំនាញបច្ចេកទេស និងថវិកាសុំឯកភាព ។

រយៈកាលកន្លងមកក្រសួងសុខាភិបាលបានសហការយ៉ាងជិតស្និទ្ធជាមួយ វិទ្យាស្ថានជាតិស្ថិតិ នៃក្រសួងផែនការដែលធ្វើអោយមតិអន្តរជាតិគេមានជំនឿលើលទ្ធផលអង្កេតរបស់យើង ។ តែបើក្រសួងសុខាភិបាលធ្វើតែឯងប្រហែលលំបាកដែរ ។ ដូចជាប៉ុន្មានថ្ងៃមុននេះមានកាសែតផ្សាយពី Prevalence នៃជំងឺ AIDS ដែលខុសពីលទ្ធផល នៃការអង្កេត ប្រជាសាស្ត្រ និងសុខភាពឆ្នាំ២០០៥ ដែលក្រសួងសុខាភិបាលបានសហការជាមួយ វិទ្យាស្ថានជាតិស្ថិតិ ព្រមទាំងមានការចូលរួមពីដៃគូអភិវឌ្ឍន៍ ។ ដល់ពេលខ្ញុំសួរទៅគាត់ ( លោក មាន ឈឺវុន ) គាត់ឆ្លើយថា ការធ្វើសន្និសីទកាសែតនោះមុនពេលយើងផ្សព្វផ្សាយលទ្ធផលនៃការអង្កេតប្រជាសាស្ត្រ និងសុខភាពនេះ ព័និតគាត់ គឺដៃម្ខាងចង់បានកិត្តិយស

ដៃម្ខាងទៀតចង់បានជំនួយ ។ តែទោះជាយ៉ាងណាមតិអន្តរជាតិគេជឿលើលទ្ធផលអង្កេតប្រជាសាស្ត្រ និងសុខភាព ឆ្នាំ២០០៥យើងហើយ ។

- មតិឯកឧត្តម ប៊ុន អ៊ុយ រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី សុំគាំទ្រទាំងស្រុងចំពោះវិទ្យាស្ថានជាតិស្ថិតិ និងថ្នាក់ដឹកនាំក្រសួងផែនការដែលបានខិតខំកសាងផែនការមេស្ថិតិ ទោះលំបាកយ៉ាងណាក៏សម្រេចបាន ហើយពេលនេះបានដាក់ឆ្លងក្រុមប្រឹក្សាស្ថិតិដើម្បីសំរេច ខ្ញុំសូមសួរបើក្នុងការអនុវត្តផែនការមេស្ថិតិបានកំណត់ច្បាស់អំពីការធ្វើជំរឿនប្រជាពលរដ្ឋ ឆ្នាំ២០០៨ ទាំងថវិកា ទាំងពេលវេលា ឃើញថាវាជាន់ជាមួយ នឹងការបោះឆ្នោតជាតិ តើគិតយ៉ាងដូចម្តេចដែរ? មួយទៀតការងារស្ថិតិ ដូចជាគេមិនសូវចាប់អារម្មណ៍ទេ ព្រោះគេមិនសូវយល់ ដូច្នេះគួរធ្វើការបណ្តុះបណ្តាលស្ថាប័នអោយគេយល់ហើយការបណ្តុះបណ្តាល គឺត្រូវការថវិកា ដឹងហើយថាមានដៃគូអភិវឌ្ឍន៍ជួយ ។

- ឯកឧត្តម ឡា ណារ៉ាត់ រដ្ឋលេខាធិការក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ : ប្រព័ន្ធព័ត៌មានសំខាន់ណាស់ ហើយវិទ្យាស្ថានជាតិស្ថិតិមានប្រើ Software ជាការល្អសំរាប់ផ្សព្វផ្សាយ និងការប្រមូលទិន្នន័យបានប្រសើរដូចសព្វថ្ងៃ ការប្រមូលទិន្នន័យមិនទាន់បានទាំងអស់ទេ ម្យ៉ាងទៀត ការទាមទារការងារ សតិអារម្មណ៍របស់មន្ត្រី គួរលើកទឹកចិត្តមន្ត្រីធ្វើការងារស្ថិតិ ( ចូលកន្សោមអាទិភាព ) ផងដែរ ។

- លោក ទេត បារ៉ុម : ភារកិច្ចរបស់ក្រុមប្រឹក្សាស្ថិតិ លើការងារផែនការមេស្ថិតិ ក្នុងនោះការស្វែងរកថវិកាសុំឯកភាពដូចផែនការមេស្ថិតិ ហើយថវិកាសំរាប់ជំរឿនប្រជាពលរដ្ឋ ប្រហែលជាមិនលំបាក តែថវិកាសំរាប់ស្ថិតិអាទិភាពប្រហែលជាលំបាក ។

មួយទៀតមានការស្រាវជ្រាវដែលផ្អែកលើគុណភាពទិន្នន័យ (Qualitative ) និងការប្រើប្រាស់ទិន្នន័យជំរឿនអង្កេត ។ កន្លងមកយើងខ្ញុំក៏ប្រមូលខ្លះដែរ វិទ្យាស្ថានជាតិស្ថិតិ ក៏ប្រមូលទិន្នន័យ ហើយវិធីសាស្ត្រក្នុងការប្រមូលមួយរយៈកន្លងមក អង្គភាពស្ថិតិជាច្រើនមានការពាក់ព័ន្ធ ។ លើវិធីសាស្ត្រប្រមូលគួរធ្វើការ "សម្របសម្រួលគ្នា" ចែករំលែកគ្នា ផ្តល់ឱ្យគ្នា ជៀសវាងការមិនស៊ីសង្វាក់គ្នា ។

ឯកឧត្តម អគ្គនាយកវិទ្យាស្ថានជាតិស្ថិតិឆ្លើយ នឹងសំនួរ :

ចំពោះការងារជំរឿនប្រជាពលរដ្ឋ មិនមានបញ្ហាអ្វីទេព្រោះយើងធ្លាប់មានបទពិសោធន៍ម្តងហើយកាលពី ឆ្នាំ១៩៩៨ ពីពេលវេលាជំរឿន ៣មីនា ឆ្នាំ១៩៩៨ និងបោះឆ្នោត ខែមិថុនា ឆ្នាំ១៩៩៨ យើងបានធ្វើជំរឿនហើយរាជរដ្ឋាភិបាលបានរៀបចំការបោះឆ្នោត គឺប្រព្រឹត្តទៅយ៉ាងរលូន ។ ជំរឿនត្រូវបានកំណត់ ( តាមអនុក្រឹត្យដែលបានចូលជាធរមានកាលពីដើមឆ្នាំ ២០០៦ ) យកម៉ោង ០ ថ្ងៃទី៣ ខែមីនា ឆ្នាំ២០០៨ រីឯថវិកាបានទទួលគ្រប់គ្រាន់ហើយ ( ពី UNFPA JICA រដ្ឋាភិបាលអាល្លឺម៉ង់ និងរដ្ឋាភិបាលជប៉ុន ) និងថវិកាបដិភាគជាង ៧00,000 US$ ( ទិញឡានម៉ូតូ ) ។ រីឯស្ថានភាព បរិយាកាសសំរាប់ធ្វើជំរឿន គឺខែនោះប្រជាពលរដ្ឋគាត់រួចរាល់ពីការងារកសិកម្ម ។ ហើយចំពោះជំរឿនកសិកម្មឆ្នាំ ២០០៩ បញ្ហាថវិកាយើងបន្ត ទំនាក់ទំនងជាមួយ CIDA (Canada ) យើងមានពេលវែងទៀត ហើយបើសិន Canada ពេញព្រមជួយ ចំពោះការងារបច្ចេកទេសអង្គការ FAO ធានាជួយហើយ ដូច្នេះបើថវិកាដោះស្រាយបាន ជំរឿនកសិកម្ម ២០០៩ នឹងអាចដំណើរការបាន ។

-បញ្ហាជំរឿនសហគ្រាស ពេលនេះ JICA កំពុងជួយអោយយើងធ្វើអង្កេតសហគ្រាសជាទិសដៅ ប្រហែលជា JICA ជួយការធ្វើជំរឿនសហគ្រាសទៀត នៅគំរោង JICA ដំណាក់កាលទី ៣ ។ (ឆ្នាំ ២០១០ គំរោង JICA ដំណាក់កាល ទី ២ត្រូវចប់ ) ។

-ចំពោះសាកលវិទ្យាល័យភូមិន្ទភ្នំពេញ វិទ្យាស្ថានជាតិស្ថិតិបានសហការយ៉ាងច្រើនជាពិសេសលើការស្រាវជ្រាវ Qualitative ហើយស្ថិតិពឹងផ្អែកលើការវាស់វែង Quantitative ដូច្នេះបំពេញបន្ថែមគ្នាទៅវិញទៅមក ហើយសុំគាំទ្រមតិលោក តំណាងសាកលវិទ្យាល័យដែលលើកឡើង "ការសម្របសម្រួលគ្នា" គឺការសំខាន់ ។ ចំពោះការប្រមូលទិន្នន័យពេលនេះយើងមានច្បាប់ស្ថិតិគឺមានការងាយស្រួលជាងមុនដែរហើយយើងកំពុងផ្សព្វផ្សាយច្បាប់ស្ថិតិអោយគ្រប់មជ្ឈដ្ឋានបានយល់ជ្រាបដែរ អំពីការឆ្លើយ ការរក្សាការសម្ងាត់ព័ត៌មានបុគ្គល ការដាក់ទោសទណ្ឌ ។ល។ យើងគ្មានបំណងដាក់ទោសពៃរ៍លើអ្នកឆ្លើយ តែយើងក៏ទាមទារនូវចម្លើយត្រឹមត្រូវ គួរជឿទុកចិត្តបាន និងទាន់ពេលវេលា នេះចំពោះគោលការណ៍របស់យើងជាអ្នកផលិតទិន្នន័យស្ថិតិជូន អ្នកប្រើប្រាស់អោយបានប្រសិទ្ធភាព ។

-ចំពោះថវិកាដែលឧបត្ថម្ភដោយដៃគូអភិវឌ្ឍន៍ ពីមុនយើងមានភាពមិនច្បាស់លាស់ តែពេលនេះដូចជាប្រាកដនិយមច្រើនព្រោះសព្វថ្ងៃដូច SIDA កំពុងជួយដំណើរការអង្កេតសេដ្ឋកិច្ច សង្គមកិច្ច ២០០៦ - ២០០៧ JICA ជួយជំរឿន ឧទាហរណ៍ : ដូចជាការសាងសង់អាគារជំរឿននៅក្នុងបរិវេណ ក្រសួងផែនការ ធានាគារពិភពលោក មានទីប្រឹក្សាប្រចាំនៅវិទ្យាស្ថានជាតិស្ថិតិជួយការងារខាងបណ្តុះបណ្តាល ។ល។

ចំពោះធនធានមនុស្សស្ថិតនៅលើការបណ្តុះបណ្តាលជាប្រចាំ ។ ដូច្នេះក្នុងកម្មវិធីអង្គប្រជុំយើងនេះក៏មានឯកសារមួយដាក់ជូនពិនិត្យដែរ ។

មតិបូកសរុបឯកឧត្តមប្រធានអង្គប្រជុំ :

ស្ថិតិ ជាជំនាញលំបាកណាស់ និយាយពីស្ថិតិគឺតម្រូវការគណិតវិទ្យា ជ្រៅជ្រះមក គណនាដោះស្រាយ បើខ្ញុំធ្លាប់ដឹងវិស្វករស្ថិតិមានតិចតួចណាស់ ។ ការធ្វើផែនការអភិវឌ្ឍន៍ទាំងរបស់រដ្ឋ ក៏ដូចឯកជនគឺត្រូវការព័ត៌មានស្ថិតិ បើគ្មានស្ថិតិទេយើងមិនអាចវាស់វែងការអភិវឌ្ឍន៍បានឡើយ ។ ធ្វើផែនការជាមួយនឹងស្ថិតិ គឺជាផែនការប្រកបដោយវិទ្យាសាស្ត្រ ប្រាកដនិយម ជាក់លាក់ និងប្រសិទ្ធភាព ផ្ទុយទៅវិញធ្វើការងារផែនការដោយគ្មានស្ថិតិ គឺផែនការផ្សងព្រេង និងគ្មានម្ចាស់ការ ។ ទោះបីស្ថិតិតម្រូវការទីផ្សារមិនសូវមានមែន តែរដ្ឋ និងក្រុមហ៊ុនឯកជនត្រូវការចាំបាច់ណាស់ ។ ទាក់ទងទៅ នឹងផែនការមេស្ថិតិ យើងបានកសាងហើយការអនុវត្តន៍ និងដំណើរការនាពេលខាងមុខដោយផ្អែកលើលិខិតបទដ្ឋាន គតិយុត្តដែលយើងបានចេញជាច្រើនមាន (ច្បាប់ស្ថិតិអនុក្រឹត្យពាក់ព័ន្ធ) ។ ចំណែកបច្ចេកទេសយើងក៏បានពង្រឹងពង្រីកបានខ្លះៗហើយ ( JICA ជួយ ) អាចផលិតស្ថិតិជូនអ្នកធ្វើផែនការប្រកបដោយប្រសិទ្ធភាពជាក់ណាត់ ។ គោលដៅស្ថិតិយើងគឺតម្រង់ទៅរកគុណភាព និងត្រូវបានទទួលស្គាល់ជឿទុកចិត្តពីគ្រប់មជ្ឈដ្ឋាន ។ ដូចឯកឧត្តមលោកជំទាវ បានពិនិត្យរួចហើយ គឺផែនការមេស្ថិតិ បានបញ្ចូលគ្រប់សមាសភាពស្ថិតិមានស្ថិតិអាទិភាព ស្ថិតិផ្លូវការដែលបានចាត់តាំង ថវិកាសំរាប់ដំណើរការស្ថិតិ ហើយក្នុងសម័យប្រជុំនេះ គឺដើម្បីឆ្លងរួចផ្ញើទៅរាជរដ្ឋាភិបាលពិនិត្យ និងអនុម័ត ។

ចំណែកឯ ឯកឧត្តមរដ្ឋលេខាធិការនៃបណ្តាក្រសួងដែលអវត្តមាន យើងក៏សូមជំរាបតាមរយៈកំណត់ហេតុអង្គប្រជុំនេះអោយគេពិនិត្យលើឯកសារ "ផែនការមេស្ថិតិ " ដែលយើងបានផ្ញើជាមួយនឹងលិខិតអញ្ជើញឱ្យមកប្រជុំនៅពេលនេះដោយឱ្យផ្ញើសំណូមពរបន្ថែម ឬ អនុសាសន៍ដែលអង្គភាពទាំងនោះមានបំណង ហើយផ្ញើមកវិទ្យាស្ថាន ជាតិស្ថិតិដើម្បីដាក់បញ្ចូលទៅក្នុងផែនការមេស្ថិតិជូន តែបើគេមិនមានអនុសាសន៍អ្វីទេ បានសេចក្តីថាបណ្តាអង្គភាពអវត្តមានទាំងនេះបានឯកភាព ផែនការមេស្ថិតិយើងនេះដែរ ។

អង្គប្រជុំទាំងមូលបានឯកភាពជាឯកច្ឆ័ន្ទនៅលើសេចក្តីព្រាងរបស់ផែនការមេស្ថិតិ ។

អង្គប្រជុំបានបញ្ចប់សព្វគ្រប់នៅវេលាម៉ោង ១១: ៤៥នាទី ថ្ងៃខែឆ្នាំដដែល ។

បានឃើញ និងឯកភាព
ភ្នំពេញថ្ងៃទី ១៧ ខែសីហា ឆ្នាំ ២០០៧
ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងផែនការ
និងជាប្រធានអង្គប្រជុំ

ឆាយ ថន

ភ្នំពេញថ្ងៃទី ១៧ ខែសីហា ឆ្នាំ ២០០៧
អ្នកធ្វើកំណត់ហេតុ

សន-ស៊ីថន

ចម្លងជូន:

-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ទីស្តីការគណៈរដ្ឋមន្ត្រី
-សមាជិក សមាជិកា ក្រុមប្រឹក្សាស្ថិតិ
-ឯកសារ កាលប្បវត្តិ